# I - រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ២២ អនក្រ.បក**

**ស្តីពីការ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាស**

**សាធារណៈសំរាប់និញដែកមេឡេ និង ស្ត្រៀងចក្រសាងសង់ផ្លូវ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ :** អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ លើមុខសញ្ញាដូចខាងក្រោម ÷

-ក្រសួងសាធារណការនិងដឹកជញ្ជូន :

+ បំពាក់គ្រឿងចក្រសាងសង់ផ្លូវ ចំនួន 1.000.000USD (មួយលានដុល្លារអាមេរិក)

+ ទិញដែកបេឡេ និង រថយន្ត ១០គ្រ. ចំនួន 1.000.000USD (មួយលានដុល្លារអាមេរិក)

-ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ :

+ ទិញដែកបេឡេ សំរាប់ស្ពានធារាសាស្ត្រ ២០០ម ចំនួន 150.000 USD (មួយរយហាសិបពាន់ ដុល្លារអាមេរិក)

ចំនួនទឹកប្រាក់ពិតប្រាកដ នឹងកំណត់ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |